00942776

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02/08/2013
ម៉ោង (Time/Heure): 8:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ពុធ ទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

**សវនាការលើអង្គសេចក្ដី-ថ្ងៃ ១៩៦**

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង **Matteo CRIPPA**

---

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក Tarik ABDULHAK, លោក Keith REYNOR |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី Beini YE, លោក ឡោ ជុនធី |
| សាក្សី៖ លោក នូ ម៉ៅ ហៅ មោក (TCW-801) |

| |
|---|
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុធារី |
| ផ្សេងៗ៖ លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី), លោក Grant RAGLAND |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៥.២០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៥០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ១០ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការតាំងសំណួរទៅសាក្សី នូ ម៉ៅ ហៅ មោក (TCW-801) | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.១៦ |
| | សហព្រះរាជអាជ្ញា | ០៩.១៦ | ១០.៣៩ |
| | សហព្រះរាជអាជ្ញា | ១១.០១ | ១២.០១ |
| | សហព្រះរាជអាជ្ញា | ១៣.៣០ | ១៣.៥៤ |
| | មេធាវីនាំមុខតំណាង ដ.រ.ណ | ១៣.៥៤ | ១៤.២៧ |
| | មេធាវីការពារក្ដី នួន ជា | ១៤.៥៤ | ១៥.១៦ |
| ការផ្អាកសវនាការមុនពេលកំណត់ | អង្គជំនុំជម្រះ | ១៥.១៧ | ១៥.២០ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនដែលនៅពីក្រោមសាលសវនាការនេះតាមវិធាន ៨១.៥ និង ផ្អែកតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ (ឯកសារ E256/5) ។

**ការតាំងសំណួរទៅសាក្សី នូ ម៉ៅ ហៅ មោក (TCW-801)**

អង្គជំនុំជម្រះបានតាំងសំណួរបឋមអំពីសាវតា និងប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចដល់សាក្សី នូ ម៉ៅ ហៅ មោក(TCW-801)។ បន្ទាប់មកសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដី នួន ជា បានតាំងសំណួរ និងបញ្ចប់ការតាំងសំណួរទៅសាក្សី នូ ម៉ៅ ហៅ មោក (TCW-

801)។

**ការផ្អាកសវនាការមុនពេលកំណត់**

ដោយសារតែសាក្សី នូ ម៉ៅ ហៅ មោក មានបញ្ហាសុខភាព អង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការមុនពេលកំណត់។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/4625 | D313/1.2.405 | 00909936-00909965 00419458-00419485 00893546-00893564 | បទសម្ភាសន៍ជាមួយ នូ មោក (NOU Mouk), 26/8/81 Interview with NOU Mouk, Oudong, 26/8/81 Interview with NOU Mouk, Oudong, 26/8/81 | P | 00909939, 00909943, 00909936, 00909944, 00909941 | 00419458, 00419464, 00419465, 00419463 | 00893548, 00893550, 00893546, 00893551, 00893549 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញជូនសាក្សី នូ ម៉ៅ ហៅ មោក (TCW-801) ត្រឡប់ទៅកន្លែងស្នាក់នៅរបស់គាត់ និងឱ្យនាំគាត់ត្រឡប់មកបន្ទប់សវនាការវិញនៅថ្ងៃព្រហស្បតិ៍ ទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឱ្យបានមុនម៉ោង ០៩ ព្រឹក។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងឱ្យនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់មកបន្ទប់សវនាការវិញ ចំណែកជនជាប់ចោទ នួន ជា មកកាន់បន្ទប់ឃុំខ្លួននៅពីខាងក្រោមសាលសវនាការនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ ឱ្យបានមុនម៉ោង ០៩ ព្រឹក។

**ដីកាសម្រាប់ការលើកវារកាលសវនាការ**

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បតិ៍ ទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ វេលាម៉ោង ៩.០០ ព្រឹក ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលទុន្នី Matteo CRIPPA